**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ**

# សារលិខិតរំលែកមរណទុក្ខ

## ផ្ញើជូន

## ឯកឧត្តម ឈៀង យ៉ាណារ៉ា ព្រមទាំងក្រុមគ្រួសារ

ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ ជាទីរាប់អាន !

ខ្ញុំ និងភរិយា ពិតជាមានសេចក្ដីក្ដុកក្ដួល រន្ធត់តក់ស្លុត និងសោកស្ដាយឥតឧបមា ដោយបានទទួលដំណឹងដ៏ក្រៀមក្រំថា លោកជំទាវ មហាឧបាសិកា **ឈិន រ៉ែម** ជាធម្មសីលានុរក្ខិតានី អគ្គមហាឧបាសិកាពុទ្ធសាសនូបត្ថម្ភក៏ ដែលត្រូវជាភរិយារបស់ឯកឧត្តម បានទទួលមរណភាពនាថ្ងៃអង្គារ ៧រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩ ត្រូវនឹងថ្ងៃទី១៤ ខែតុលា ឆ្នាំ២០២៥ វេលាម៉ោង០៦:១៥នាទី ក្នុងជន្មាយុ៧១ឆ្នាំ ដោយរោគាពាធ។

មរណភាពរបស់លោកជំទាវ មហាឧបាសិកា **ឈិន រ៉ែម** មិនត្រឹមតែជាការបាត់បង់នូវភរិយា ដែលប្រកបដោយសង្គហធម៌ដ៏ឧត្តុង្គឧត្តមចំពោះស្វាមី និងជាការបាត់បង់នូវម្ដាយ ម្ដាយក្មេក និងជីដូន ដែលប្រកបដោយព្រហ្មវិហារធម៌ចំពោះកូនៗ និងចៅៗប៉ុណ្ណោះទេ ប៉ុន្តែគឺជាការបាត់បង់ដ៏ធំធេងនូវសីលវតី ដែលអនុវត្តយ៉ាងខ្ជាប់ខ្ជួននូវត្រៃសរណគមន៍ប្រកបដោយវីរិយភាពដ៏ខ្ពង់ខ្ពស់បំផុត។

ក្នុងវេលាប្រកបដោយសមានទុក្ខដ៏ក្រៀមក្រំបំផុតនេះ ខ្ញុំនិងភរិយា សូមចូលរួមរំលែកមរណទុក្ខជាមួយ **ឯកឧត្តម ព្រមទាំងក្រុមគ្រួសារ** ដោយសេចក្តីអាឡោះអាល័យរកអ្វីប្រៀបផ្ទឹមពុំបានចំពោះការបាត់បង់ដ៏ធំធេងនេះ និងសូមបួងសួងដល់វត្ថុស័ក្តិសិទ្ធិក្នុងលោក និងតេជះបារមីនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ សូមតាមបីបាច់ថែរក្សាដល់ដួងវិញ្ញាណក្ខន្ធរបស់លោកជំទាវ មហាឧបាសិកា **ឈិន រ៉ែម** សូមបានដល់ឋានបរមសុខ និងឆាប់បានយោនយកកំណើតកើតក្នុងសុគតិភពគ្រប់ៗជាតិ កុំបីឃ្លៀងឃ្លាតឡើយ។

សូម ឯកឧត្តម ឈៀង យ៉ាណារ៉ា ព្រមទាំងក្រុមគ្រួសារ ទទួលនូវការរាប់អានដ៏ជ្រាលជ្រៅពីខ្ញុំនិងភរិយា។

ថ្ងៃព្រហស្បតិ៍ ៩រោច ខែអស្សុជ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២៥

**នាយឧត្តមសេនីយ៍ ទៀ សីហា**